**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តស្វាយរៀង**

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តស្វាយរៀង

-សំណុំរឿងព្រហ្មទណ្ឌ
លេខ ៤៣២
ចុះថ្ងៃទី ៣០-១០-២០២៣
-សំណុំរឿងជំនុំជម្រះ
លេខ ១១៤
ចុះថ្ងៃទី ១-០៤-២០២៣
-សាលក្រមព្រហ្មទណ្ឌ
លេខ ២៧/២០២៤ (ត)
ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២៤

បានបើកសវនាការជាសាធារណៈ នៅសាលសវនាការ នៃសាលាដំបូងខេត្តស្វាយរៀង នាថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៤ វេលាម៉ោង០២ និង៣០នាទីរសៀល ដោយមានសមាសភាពជំនុំជម្រះដូចតទៅ៖

**<u>ចៅក្រមជំនុំជម្រះ</u>**

-លោក [redacted] អនុប្រធានសាលាដំបូងខេត្តស្វាយរៀង

**<u>តំណាងអយ្យការ</u>**

-លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តស្វាយរៀង

**<u>ក្រឡាបញ្ជីសវនាការ</u>**

-លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តស្វាយរៀង

**<u>ដើម្បីជំនុំជម្រះ</u>**

លើសំណុំរឿងព្រហ្មទណ្ឌលេខ ៤៣២ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៣ ដែលមាន៖

១-ជនជាប់ចោទឈ្មោះ [redacted] ចាន់ ភេទប្រុស អាយុ៤៤ឆ្នាំ ជនជាតិខ្មែរ មុខរបរបុគ្គលិកមន្ត្រីឥណទានសហគ្រាសហាងបញ្ចាំម៉ូតូអូហាយ៉ូប៊ីស សាសនាព្រះពុទ្ធ មានទីកន្លែងកំណើតនៅភូ[redacted] ខេត្តកំពង់ចាម អាសយដ្ឋានបច្ចុប្បន្ននៅភូមិអំពិលលើ ឃុំអំពិល ស្រុកកំពង់សៀម ខេត្តកំពង់ចាម ឪពុកឈ្មោះ[redacted] ត្រេន "ស" ម្តាយឈ្មោះ [redacted] សារឿន "រ" ប្រពន្ធឈ្មោះ [redacted] អាត មានកូនចំនួន០៤នាក់ កម្រិតវប្បធម៌ថ្នាក់ទី១២ ជានីតិជន ប្រវត្តិផ្តន្ទាទោសដោយតុលាការពីមុន គ្មាន ។

*-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១៣២៥ ប.ឃខ/២៣ ចុះថ្ងៃទី៣០-១០-២០២៣ ។*

-មានលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

ជាប់ចោទពីបទ **សមគំនិតក្នុងអំពើឆបោក** ប្រព្រឹត្តនៅភូមិកំពោតជ្រូក សង្កាត់ព្រៃអង្គុញ ក្រុងបាវិត ខេត្តស្វាយរៀង កាលពីអំឡុងឆ្នាំ២០២២ និងអំឡុងឆ្នាំ២០២៣ បទល្មើសដែលមានចែងនិងបញ្ញត្តឱ្យផ្តន្ទាទោសតាមមាត្រា ២៩ មាត្រា ៣៧៧ មាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

២-ជនជាប់ចោទឈ្មោះ [redacted]ផល្លី ហៅ រស់ ភេទប្រុស អាយុ៤០ឆ្នាំ ជនជាតិខ្មែរ មុខរបរអគ្គនាយកសហគ្រាស ហាងបញ្ចាំម៉ូតូ អូហាយ៉ូប៊ិស សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅ [redacted] ខេត្តកំពង់ចាម អាសយដ្ឋានបច្ចុប្បន្នភូមិដីថ្មី ឃុំព្រៃសាម៉ាន់ ស្រុកឆ្លូង ខេត្តក្រចេះ ឪពុកឈ្មោះ[redacted] ឡាង "រ" ម្តាយឈ្មោះ[redacted]សារឿន "ស" ប្រពន្ធឈ្មោះ[redacted] ថាវី "រ" មានកូនចំនួន០៣នាក់ ជានីតិជន ទោសពីមុន គ្មាន ។ (គេចខ្លួន)

-ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ៥០ បត.ចខ/២៤ ចុះថ្ងៃទី២៩-១-២០២៤ ។



Scanned with CamScanner

-មានលោកមេធាវី [redacted] និងលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

ជាប់ចោទពីបទ **ឆបោក** ប្រព្រឹត្តនៅភូមិកំពោតជ្រូក សង្កាត់ព្រៃអង្គុញ ក្រុងបាវិត ខេត្តស្វាយរៀង កាលពីអំឡុងឆ្នាំ២០២២ និងអំឡុងឆ្នាំ២០២៣ បទល្មើសដែលមានចែងនិងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

**ដើមបណ្តឹងរដ្ឋប្បវេណី៖**

១-ឈ្មោះ [redacted] សុវណ្ណារ៉ា ភេទប្រុស អាយុ៣១ឆ្នាំ ជនជាតិខ្មែរ មុខរបរអាជីវករ មានទីលំនៅបច្ចុប្បន្ននៅភូមិពោធិ៍ ឃុំមេសរថ្ងក ស្រុកចន្ទ្រា ខេត្តស្វាយរៀង ។

២-ឈ្មោះ [redacted] គន្ធា ភេទស្រី អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ មុខរបរអាជីវករ មានទីលំនៅបច្ចុប្បន្ននៅភូមិអង្គស្លា សង្កាត់ព្រៃអង្គុញ ក្រុងបាវិត ខេត្តស្វាយរៀង ។

៣-ឈ្មោះ [redacted] ធឿន ភេទស្រី អាយុ៦៦ឆ្នាំ ជនជាតិខ្មែរ មុខរបរអាជីវករ មានទីលំនៅបច្ចុប្បន្ននៅភូមិពោធិ៍ ឃុំមេសរថ្ងក ស្រុកចន្ទ្រា ខេត្តស្វាយរៀង ។

៤-ឈ្មោះ [redacted] នាត ភេទស្រី អាយុ៦៦ឆ្នាំ ជនជាតិខ្មែរ មុខរបរអាជីវករ មានទីលំនៅបច្ចុប្បន្ននៅភូមិថ្នល់កែង សង្កាត់បាទី ក្រុងបាវិត ខេត្តស្វាយរៀង ។

៥-ឈ្មោះ [redacted] សាផាន ភេទស្រី អាយុ៦៥ឆ្នាំ ជនជាតិខ្មែរ មុខរបរអាជីវករ មានទីលំនៅបច្ចុប្បន្ននៅភូមិពោធិ៍ ឃុំមេសរថ្ងក ស្រុកចន្ទ្រា ខេត្តស្វាយរៀង ។

៦-ឈ្មោះ [redacted] សាវ៉ន ភេទស្រី អាយុ៤៣ឆ្នាំ ជនជាតិខ្មែរ មុខរបរអាជីវករ មានទីលំនៅបច្ចុប្បន្ននៅភូមិពោធិ៍ ឃុំមេសរថ្ងក ស្រុកចន្ទ្រា ខេត្តស្វាយរៀង ។

៧-ឈ្មោះ [redacted] សាមី ភេទស្រី អាយុ៥២ឆ្នាំ ជនជាតិខ្មែរ មុខរបរអាជីវករ មានទីលំនៅបច្ចុប្បន្ននៅភូមិដីក្រហម ឃុំមេសរថ្ងក ស្រុកចន្ទ្រា ខេត្តស្វាយរៀង ។

៨-ឈ្មោះ [redacted] សិរី ភេទស្រី អាយុ២២ឆ្នាំ ជនជាតិខ្មែរ មុខរបរអាជីវករ មានទីលំនៅបច្ចុប្បន្ននៅភូមិពោធិ៍ ឃុំមេសរថ្ងក ស្រុកចន្ទ្រា ខេត្តស្វាយរៀង ។

៩-ឈ្មោះ [redacted] សុវណ្ណ ភេទស្រី អាយុ៥១ឆ្នាំ ជនជាតិខ្មែរ មុខរបរអាជីវករ មានទីលំនៅបច្ចុប្បន្ននៅភូមិដីក្រហម ឃុំមេសរថ្ងក ស្រុកចន្ទ្រា ខេត្តស្វាយរៀង ។

១០-ឈ្មោះ [redacted] សុជាតា ភេទស្រី អាយុ២៨ឆ្នាំ ជនជាតិខ្មែរ មុខរបរអាជីវករ មានទីលំនៅបច្ចុប្បន្ននៅភូមិដីក្រហម ឃុំមេសរថ្ងក ស្រុកចន្ទ្រា ខេត្តស្វាយរៀង ។

១១-ឈ្មោះ [redacted] ប៊ុនញ៉ាក ភេទស្រី អាយុ៣០ឆ្នាំ ជនជាតិខ្មែរ មុខរបរអាជីវករ មានទីលំនៅបច្ចុប្បន្ននៅភូមិដីក្រហម ឃុំមេសរថ្ងក ស្រុកចន្ទ្រា ខេត្តស្វាយរៀង ។

១២-ឈ្មោះ [redacted] សារ៉េម ភេទស្រី អាយុ២៩ឆ្នាំ ជនជាតិខ្មែរ មុខរបរអាជីវករ មានទីលំនៅបច្ចុប្បន្ននៅភូមិកំពោតរលៀប សង្កាត់ព្រៃអង្គុញ ក្រុងបាវិត ខេត្តស្វាយរៀង ។

១៣-ឈ្មោះ [redacted] សាបុល ភេទស្រី អាយុ៣៩ឆ្នាំ ជនជាតិខ្មែរ មុខរបរអាជីវករ មានទីលំនៅបច្ចុប្បន្ននៅភូមិកំពោតរលៀប សង្កាត់ព្រៃអង្គុញ ក្រុងបាវិត ខេត្តស្វាយរៀង ។



Scanned with CamScanner

**១៤-ឈ្មោះ** [redacted]**ផារ៉ា** ភេទស្រី អាយុ៤២ឆ្នាំ ជនជាតិខ្មែរ មុខរបរអាជីវករ មានទីលំនៅបច្ចុប្បន្ននៅភូមិគោកល្បៀង សង្កាត់ព្រៃអង្គុញ ក្រុងបាវិត ខេត្តស្វាយរៀង ។

**១៥-ឈ្មោះ** [redacted] **មករា** ភេទស្រី អាយុ៣៩ឆ្នាំ ជនជាតិខ្មែរ មុខរបរអាជីវករ មានទីលំនៅបច្ចុប្បន្ននៅភូមិព្រៃអង្គុញ សង្កាត់ព្រៃអង្គុញ ក្រុងបាវិត ខេត្តស្វាយរៀង ។

**១៦-ឈ្មោះ** [redacted] **សំអន** ភេទប្រុស អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ មុខរបរអាជីវករ មានទីលំនៅបច្ចុប្បន្ននៅភូមិព្រៃអង្គុញ សង្កាត់ព្រៃអង្គុញ ក្រុងបាវិត ខេត្តស្វាយរៀង ។

**១៧-ឈ្មោះ** [redacted] **សុរិយា** ភេទស្រី អាយុ៣៤ឆ្នាំ ជនជាតិខ្មែរ មុខរបរអាជីវករ មានទីលំនៅបច្ចុប្បន្ននៅភូមិគោកល្បៀង សង្កាត់ព្រៃអង្គុញ ក្រុងបាវិត ខេត្តស្វាយរៀង ។

**១៨-ឈ្មោះ** [redacted]**សាផា** ភេទស្រី អាយុ៤០ឆ្នាំ ជនជាតិខ្មែរ មុខរបរអាជីវករ មានទីលំនៅបច្ចុប្បន្ននៅភូមិច្រកម្ទេស សង្កាត់ច្រកម្ទេស ក្រុងបាវិត ខេត្តស្វាយរៀង ។

**១៩-ឈ្មោះ** [redacted] **លន់** ភេទស្រី អាយុ៤៦ឆ្នាំ ជនជាតិខ្មែរ មុខរបរអាជីវករ មានទីលំនៅបច្ចុប្បន្ននៅភូមិច្រកម្ទេស សង្កាត់ច្រកម្ទេស ក្រុងបាវិត ខេត្តស្វាយរៀង ។

**-បានឃើញ** របាយការណ៍សរុបលេខ **១១៥ របក** ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៣ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាល នៃស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង ។

**-បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ **៣២២ ដស.បស** ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តស្វាយរៀង ។

**-បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ **៤២ អ.យ.ច** ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៤ របស់តំណាងអយ្យការអមសាលាដំបូងខេត្តស្វាយរៀង ។

**-បានឃើញ** ដីកាដំណោះស្រាយលេខ ៣២១ (ច) ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៤ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តស្វាយរៀង ។

**-បានឃើញ** ដីកាសម្រេចចាត់តាំងចៅក្រមជំនុំជម្រះលេខ **១១៩ ដ.ស.រ/២៤** ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០២៤ របស់ប្រធានសាលាដំបូងខេត្តស្វាយរៀង ។

## អង្គហេតុដែលកើតមានឡើង

កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៣ សមត្ថកិច្ចប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់ព្រៃអង្គុញ បានទទួលពាក្យបណ្តឹងពីប្រជាពលរដ្ឋចំនួន០៦គ្រួសារ ប្តឹងឈ្មោះ [redacted] ផល្លី ហៅ រស់ អគ្គនាយកសហគ្រាសហាងបញ្ចាំម៉ូតូឈ្មោះ អ៊ូហាយ៉ូប៊ីស ឈ្មោះ [redacted] ចាន់ និងបក្ខពួកពាក់ព័ន្ធនឹងករណីរំលោភលើទំនុកចិត្ត ។ ក្រោយពីបានស៊ើបអង្កេតរួចមកឃើញថា កាលពីអំឡុងឆ្នាំ២០២២ និងអំឡុងឆ្នាំ២០២៣ សាខាសហគ្រាសហាងបញ្ចាំម៉ូតូឈ្មោះ អ៊ូហាយ៉ូប៊ីស ដែលមានទីតាំងស្ថិតនៅភូមិកំពោតជ្រូក សង្កាត់ព្រៃអង្គុញ ក្រុងបាវិត ខេត្តស្វាយរៀង មានអគ្គនាយកឈ្មោះ[redacted] ផល្លី ហៅ រស់ បានទទួលប្រាក់បញ្ញើពីប្រជាពលរដ្ឋដើមបណ្តឹងទាំង០៦គ្រួសារខាងលើ ជាប្រភេទបញ្ញើដៃគូជំនួញ ដោយប្រជាពលរដ្ឋខាងលើដាក់ប្រាក់ជាប្រចាំថ្ងៃ ដាក់នៅថ្ងៃណាក៏បាន ហើយសហគ្រាសខាងលើ គិតការប្រាក់ជូនម្ចាស់ប្រាក់ ១% ក្នុងមួយខែ ហើយការព្រមព្រៀងរបស់សហគ្រាស និងប្រជាពលរដ្ឋម្ចាស់ប្រាក់ គឺម្ចាស់ប្រាក់អាចដកប្រាក់នៅពេលណាក៏បាន ដោយគ្រាន់តែជូនដំណឹងសហគ្រាសនេះមុនរយៈពេលមួយសប្តាហ៍។ ក្រោយពីទទួលបានប្រាក់បញ្ញើ សហគ្រាសខាងលើ បានយកប្រាក់បញ្ញើរបស់ប្រជា



Scanned with CamScanner

ពលរដ្ឋខាងលើទៅវិនិយោគ តាមរយៈការយកប្រាក់បញ្ញើទាំងនោះទៅឱ្យអតិថិជនរបស់ខ្លួនខ្ចីបន្ត ដើម្បីបានចំណេញ ដោយគិតការប្រាក់ពីអតិថិជន២,៥% ក្នុងរយៈពេល២សប្តាហ៍។ ក្រោយពីយកប្រាក់ខាងលើទៅវិនិយោគឱ្យអតិថិជនខ្លួនខ្ចីបន្តបែបនេះបានមួយរយៈ ប្រជាពលរដ្ឋដើមបណ្តឹងទាំង៦គ្រួសារខាងលើ បានមករកដកប្រាក់ដើម និងការប្រាក់របស់ខ្លួនពីសហគ្រាសខាងលើ ដើម្បីយកទៅប្រើប្រាស់ តែសហគ្រាសមិនមានប្រាក់សងទៅប្រជាពលរដ្ឋទាំងនោះវិញ ទើបប្រជាពលរដ្ឋប្តឹងមកសមត្ថកិច្ច ឈានដល់ការឃាត់ខ្លួនជនត្រូវចោទឈ្មោះ ឡាង ចាន់ មកសាកសួរ កសាងសំណុំរឿងបញ្ជូនមកអយ្យការ អមសាលាដំបូងខេត្តស្វាយរៀង ចាត់ការតាមនីតិវិធី ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ចាន់ បានឆ្លើយថា ដំបូងឡើយ ខាងក្រុមហ៊ុនបានបញ្ជូនខ្ញុំមកឱ្យនិយាយជាមួយភាគីជនរងគ្រោះ សុំពន្យារពេលគាត់ ហើយមកបាន២ថ្ងៃ ក៏ត្រូវគេឃាត់ខ្លួន ។ ពីមុន ខ្ញុំធ្វើការនៅខេត្តកំពង់ចាម ពីឆ្នាំ២០២០មកដល់ពេលនេះ បាន៤ឆ្នាំ ដោយកាន់តួនាទីជានាយកសាខា ហើយក្រុមហ៊ុននេះ គឺផ្តល់សេវាកម្មខ្ចីប្រាក់ ដោយឱ្យការប្រាក់ចាប់ពី១.៥ភាគរយឡើង ។ ហើយទឹកប្រាក់ដែលទទួល គឺចាប់ពី២០ម៉ឺនរៀល ដល់១លានរៀល ។ ជាគោលការណ៍លុយបង្វិល គឺ១សប្តាហ៍ ឱ្យទៅខាងអ្នកដាក់បញ្ញើ ដោយដកទាំងដើម និងការប្រាក់ ហើយដាក់បន្ត។ ចំពោះនៅខេត្តកំពង់ចាម គឺពុំមានការដាក់បញ្ញើនេះនោះទេ ។ ចំពោះប្រាក់បញ្ញើនេះ គឺនៅស្វាយរៀងនោះទេ ហើយខ្ញុំមកធ្វើការនៅខេត្តកំពង់ចាមនោះទេ តែថ្នាក់លើឱ្យខ្ញុំមកដោះស្រាយនៅខេត្តស្វាយរៀង ដោយមកនិយាយជាមួយអតិថិជនឱ្យជួយសម្របសម្រួលរឿងការងារបង្វិលប្រាក់ទៅពលរដ្ឋពុំទាន់ ។ ក្រុមហ៊ុននៅបាវិត គឺនៅបើកធម្មតា តែចំពោះសេវាកម្មបញ្ញើនេះ គឺផ្អាកទទួល។ ចំពោះរយៈពេល២ថ្ងៃដែលមកធ្វើការនៅខេត្តស្វាយរៀងនេះ គឺបានមកសម្របសម្រួលជាមួយអតិថិជន។ ហើយចំពោះចំនួនទឹកប្រាក់ គឺខ្ញុំពុំទាន់បានដឹងថា ចំនួនប៉ុន្មាននោះទេ ។ ចំពោះការដកប្រាក់ គឺនាយកសាខា អាចដកប្រាក់ចំណាយបានតិចតួច ទាល់តែនាយកធំខាងលើ បានអាចដកបានចំពោះការរកប្រាក់សងពុំបាននេះ គឺដោយសារខាងអតិថិជន ពុំបានសងមកក្រុមហ៊ុនទាន់ពេលវេលាដែរ។ ខ្ញុំមានតួនាទីជានាយកសាខា នៅខេត្តកំពង់ចាម ហើយនៅស្វាយរៀងមានការកកស្ទះរឿងប្រាក់ ក៏គេចាត់ឱ្យខ្ញុំមក ។ ចំពោះការចោទប្រកាន់នេះ ពុំត្រឹមត្រូវនោះទេ ដោយសារខ្ញុំពុំមែនជាអ្នកតួនាទីនៅខេត្តស្វាយរៀងនោះទេ គឺឈ្មោះ [redacted] សុជាតិ ជានាយកសាខានៅស្វាយរៀង ហើយឈ្មោះ [redacted] ផល្លី ជាអ្នកទទួលខុសត្រូវរួម ដោយសារគាត់ជាអគ្គនាយកក្រុមហ៊ុន ។ ចំពោះការបាត់ប្រាក់នោះ គឺខ្ញុំពុំបានដឹងនោះទេ តែដឹងត្រឹមថា លុយនោះ គឺបានយកទៅឱ្យអតិថិជនខ្ចី ហើយពួកគាត់ពុំទាន់បានសងមកក្រុមហ៊ុនវិញ តាមពេលកំណត់ ។ ហើយក៏ពុំបានរកឃើញថា មានការបាត់បង់ដោយសារការយកទៅចាយវាយផ្ទាល់ខ្លួននោះដែរ ។ ខ្ញុំមកនេះ ដើម្បីសុំការពន្យារពេល ដើរប្រមូលប្រាក់ ទៅបង្វិលជូនពួកគាត់។ ខាងក្រុមហ៊ុន ពុំបានប្តូរទីតាំងនោះទេ។ ខ្ញុំធ្វើការបានប្រាក់ខែ៤០០ដុល្លារក្នុង១ខែ ។ ហើយការងារ គឺខ្ញុំទទួលខុសត្រូវតែនៅខេត្តកំពង់ចាមនោះទេ តែខាងក្រុមហ៊ុន ក៏បានចាត់ឱ្យខ្ញុំមកដោះស្រាយបញ្ហាអតិថិជននៅខេត្តស្វាយរៀង ។ ចំពោះប្រាក់ដែលដើមបណ្តឹងប្តឹងទាមទារនោះ គឺខ្ញុំពុំបានទទួលនោះទេ ហើយអ្នកទទួល គឺបុគ្គលិកដែលធ្វើការនៅខេត្តស្វាយរៀង ។ ក្រុមហ៊ុននៅខេត្តកំពង់ចាម ខ្ញុំពុំដឹងថា មានអាជ្ញាប័ណ្ណ ឬអត់ទេ ដោយសារខ្ញុំជាបុគ្គលិកថ្នាក់ក្រោម។ ចំពោះក្រុមហ៊ុននេះ មាន៤សាខា ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុវណ្ណ បានឆ្លើយថា ខ្ញុំដាក់លុយសរុបមានចំនួន១.៤៦០.០០០រៀល ដោយបានដាក់ជាច្រើនខែហើយ ។ ចំពោះប្រាក់នោះ គឺបុគ្គលិកខាងសហគ្រាសជាអ្នកទទួល ហើយមានម្ចាស់សហគ្រាស ជា



Scanned with CamScanner

អ្នកមកជាមួយ ហើយមានកិច្ចសន្យា និងសៀវភៅ ដែលចុះ នៅពេលដែលពួកខ្ញុំដាក់ប្រាក់ និងដកប្រាក់ ។ ខ្ញុំសូមរក្សាចម្លើយ និងការទាមទារសំណងដូចដែលបានទាមទារនៅចំពោះមុខចៅក្រមស៊ើបសួរ ទុកជាបានការដដែល ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សិរី បានឆ្លើយថា ខ្ញុំដាក់លុយសរុបមានចំនួន២.០១០.០០០រៀល ដោយបានដាក់ជាច្រើនខែហើយ ។ ចំពោះប្រាក់នោះ គឺបុគ្គលិកខាងសហគ្រាសជាអ្នកទទួល ហើយមានម្ចាស់សហគ្រាស ជាអ្នកមកជាមួយ ហើយមានកិច្ចសន្យា និងសៀវភៅ ដែលចុះ នៅពេលដែលពួកខ្ញុំដាក់ប្រាក់ និងដកប្រាក់ ។ ខ្ញុំសូមរក្សាចម្លើយ និងការទាមទារសំណងដូចដែលបានទាមទារនៅចំពោះមុខចៅក្រមស៊ើបសួរ ទុកជាបានការដដែល ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាមី បានឆ្លើយថា ខ្ញុំដាក់លុយសរុបមានចំនួន២.៨០០.០០០រៀល ដោយបានដាក់ជាច្រើនខែហើយ ។ ចំពោះប្រាក់នោះ គឺបុគ្គលិកខាងសហគ្រាសជាអ្នកទទួល ហើយមានម្ចាស់សហគ្រាស ជាអ្នកមកជាមួយ ហើយមានកិច្ចសន្យា និងសៀវភៅ ដែលចុះ នៅពេលដែលពួកខ្ញុំដាក់ប្រាក់ និងដកប្រាក់ ។ ខ្ញុំសូមរក្សាចម្លើយ និងការទាមទារសំណងដូចដែលបានទាមទារនៅចំពោះមុខចៅក្រមស៊ើបសួរ ទុកជាបានការដដែល ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] គន្ធា បានឆ្លើយថា ខ្ញុំដាក់លុយសរុបមានចំនួន៦.០១៥.០០០រៀល ដោយបានដាក់ជាច្រើនខែហើយ ។ ចំពោះប្រាក់នោះ គឺបុគ្គលិកខាងសហគ្រាសជាអ្នកទទួល ហើយមានម្ចាស់សហគ្រាស ជាអ្នកមកជាមួយ ហើយមានកិច្ចសន្យា និងសៀវភៅ ដែលចុះ នៅពេលដែលពួកខ្ញុំដាក់ប្រាក់ និងដកប្រាក់ ។ ខ្ញុំចូលរួមប្តឹងដោយសារខ្ញុំដកប្រាក់ពុំបាន ហើយនៅពេលដាក់ គឺបានចំនួន១០ថ្ងៃ ហើយពេលទៅដក គឺដកពុំបាន តែក្រោយមក នៅពេលបាន៨ថ្ងៃ ហើយទៅដក ដកពុំបាន ក៏បានប្តឹងតែម្តង ។ ខ្ញុំសូមរក្សាចម្លើយ និងការទាមទារសំណងដូចដែលបានទាមទារនៅចំពោះមុខចៅក្រមស៊ើបសួរ ទុកជាបានការដដែល ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] នាត បានឆ្លើយថា ខ្ញុំដាក់លុយសរុបមានចំនួន៥១០.០០០រៀល ដោយបានដាក់ជាច្រើនខែហើយ ។ ចំពោះប្រាក់នោះ គឺបុគ្គលិកខាងសហគ្រាសជាអ្នកទទួល ហើយមានម្ចាស់សហគ្រាស ជាអ្នកមកជាមួយ ហើយមានកិច្ចសន្យា និងសៀវភៅ ដែលចុះ នៅពេលដែលពួកខ្ញុំដាក់ប្រាក់ និងដកប្រាក់ ។ ខ្ញុំសូមរក្សាចម្លើយ និងការទាមទារសំណងដូចដែលបានទាមទារនៅចំពោះមុខចៅក្រមស៊ើបសួរ ទុកជាបានការដដែល ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ធឿន បានឆ្លើយថា ខ្ញុំដាក់លុយសរុបមានចំនួន៥១០.០០០រៀល ដោយបានដាក់ជាច្រើនខែហើយ ។ ចំពោះប្រាក់នោះ គឺបុគ្គលិកខាងសហគ្រាសជាអ្នកទទួល ហើយមានម្ចាស់សហគ្រាស ជាអ្នកមកជាមួយ ហើយមានកិច្ចសន្យា និងសៀវភៅ ដែលចុះ នៅពេលដែលពួកខ្ញុំដាក់ប្រាក់ និងដកប្រាក់ ។ ខ្ញុំសូមរក្សាចម្លើយ និងការទាមទារសំណងដូចដែលបានទាមទារនៅចំពោះមុខចៅក្រមស៊ើបសួរ ទុកជាបានការដដែល ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុវណ្ណារ៉ា បានឆ្លើយថា ខ្ញុំដាក់លុយសរុបមានចំនួន២.៥៣០.០០០រៀល ដោយបានដាក់ជាច្រើនខែហើយ ។ ចំពោះប្រាក់នោះ គឺបុគ្គលិកខាងសហគ្រាសជាអ្នកទទួល ហើយមានម្ចាស់សហគ្រាស ជាអ្នកមកជាមួយ ហើយមានកិច្ចសន្យា និងសៀវភៅ ដែលចុះ នៅពេលដែលពួកខ្ញុំដាក់ប្រាក់ និងដកប្រាក់ ។ ចំពោះឈ្មោះ [redacted] ចាន់ គឺពេលខ្ញុំទៅដាក់ គឺខ្ញុំធ្លាប់ជួបគាត់ច្រើនដង ហើយដោយសារគាត់ជាបងប្អូនគ្នា ចឹង ពេលខ្លះទៅជួបគាត់ ពេលខ្លះទៅជួបបងប្អូនរបស់គាត់ តែខ្ញុំឃើញគាត់នៅធ្វើការកន្លែងនោះ ។ កន្លងមក ពួកខ្ញុំដកប្រាក់បាន គឺចំណេញ តែនៅពេលដែលដកពុំបាន ទើបធ្វើឱ្យពួកខ្ញុំខាតបង់ប្រយោជន៍ ។ ខ្ញុំសូមរក្សាចម្លើយ និងការទាមទារសំណងដូចដែលបានទាមទារនៅចំពោះមុខចៅក្រមស៊ើបសួរ ទុកជាបានការដដែល ។



Scanned with CamScanner

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ស៊ីនួន** បានឆ្លើយថា ខ្ញុំដាក់លុយសរុបមានចំនួន១.៥១០.០០០រៀល ដោយបានដាក់ជាច្រើនខែហើយ ។ ចំពោះប្រាក់នោះ គឺបុគ្គលិកខាងសហគ្រាសជាអ្នកទទួល ហើយមានម្ចាស់សហគ្រាស ជាអ្នកមកជាមួយ ហើយមានកិច្ចសន្យា និងសៀវភៅ ដែលចុះ នៅពេលដែលពួកខ្ញុំដាក់ប្រាក់ និងដកប្រាក់ ។ ខ្ញុំសូមរក្សាចម្លើយ និងការទាមទារសំណងដូចដែលបានទាមទារនៅចំពោះមុខចៅក្រមស៊ើបសួរ ទុកជាបានការដដែល ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សាវ៉ន** បានឆ្លើយថា ខ្ញុំដាក់លុយសរុបមានចំនួន២.១០០.០០០រៀល ដោយបានដាក់ជាច្រើនខែហើយ ។ ចំពោះប្រាក់នោះ គឺបុគ្គលិកខាងសហគ្រាសជាអ្នកទទួល ហើយមានម្ចាស់សហគ្រាស ជាអ្នកមកជាមួយ ហើយមានកិច្ចសន្យា និងសៀវភៅ ដែលចុះ នៅពេលដែលពួកខ្ញុំដាក់ប្រាក់ និងដកប្រាក់ ។ ខ្ញុំសូមរក្សាចម្លើយ និងការទាមទារសំណងដូចដែលបានទាមទារនៅចំពោះមុខចៅក្រមស៊ើបសួរ ទុកជាបានការដដែល ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សាផាន** បានឆ្លើយថា ខ្ញុំដាក់លុយសរុបមានចំនួន៤.៥០០.០០០រៀល ដោយបានដាក់ជាច្រើនខែហើយ ។ ចំពោះប្រាក់នោះ គឺបុគ្គលិកខាងសហគ្រាសជាអ្នកទទួល ហើយមានម្ចាស់សហគ្រាស ជាអ្នកមកជាមួយ ហើយមានកិច្ចសន្យា និងសៀវភៅ ដែលចុះ នៅពេលដែលពួកខ្ញុំដាក់ប្រាក់ និងដកប្រាក់ ។ កន្លងមក ពួកខ្ញុំធ្លាប់បានដកប្រាក់ដើម និងការប្រាក់ បានខ្លះ តែលើកចុងក្រោយនេះ បែរជាពុំអាចដកលុយបាន ហើយការដកប្រាក់ គឺពួកខ្ញុំបានជូនដំណឹងទៅខាងសហគ្រាសជាមុន ។ ខ្ញុំសូមរក្សាចម្លើយ និងការទាមទារសំណងដូចដែលបានទាមទារនៅចំពោះមុខចៅក្រមស៊ើបសួរ ទុកជាបានការដដែល ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **មករា** បានឆ្លើយថា ខ្ញុំដាក់លុយសរុបមានចំនួន៦.៨០០.០០០រៀល ដោយបានដាក់ជាច្រើនខែហើយ ។ ចំពោះប្រាក់នោះ គឺបុគ្គលិកខាងសហគ្រាសជាអ្នកទទួល ហើយមានម្ចាស់សហគ្រាស ជាអ្នកមកជាមួយ ហើយមានកិច្ចសន្យា និងសៀវភៅ ដែលចុះ នៅពេលដែលពួកខ្ញុំដាក់ប្រាក់ និងដកប្រាក់ ។ កន្លងមក ពួកខ្ញុំធ្លាប់បានដកប្រាក់ដើម និងការប្រាក់ បានខ្លះ តែលើកចុងក្រោយនេះ បែរជាពុំអាចដកលុយបាន ហើយការដកប្រាក់ គឺពួកខ្ញុំបានជូនដំណឹងទៅខាងសហគ្រាសជាមុន ។ ខ្ញុំសូមរក្សាចម្លើយ និងការទាមទារសំណងដូចដែលបានទាមទារនៅចំពោះមុខចៅក្រមស៊ើបសួរ ទុកជាបានការដដែល ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាបុល បានឆ្លើយថា ខ្ញុំដាក់លុយសរុបមានចំនួន៣.៩២៤.០០០រៀល ដោយបានដាក់ជាច្រើនខែហើយ ។ ចំពោះប្រាក់នោះ គឺបុគ្គលិកខាងសហគ្រាសជាអ្នកទទួល ហើយមានម្ចាស់សហគ្រាស ជាអ្នកមកជាមួយ ហើយមានកិច្ចសន្យា និងសៀវភៅ ដែលចុះ នៅពេលដែលពួកខ្ញុំដាក់ប្រាក់ និងដកប្រាក់ ។ កន្លងមក ពួកខ្ញុំធ្លាប់បានដកប្រាក់ដើម និងការប្រាក់ បានខ្លះ តែលើកចុងក្រោយនេះ បែរជាពុំអាចដកលុយបាន ហើយការដកប្រាក់ គឺពួកខ្ញុំបានជូនដំណឹងទៅខាងសហគ្រាសជាមុន ។ ខ្ញុំសូមរក្សាចម្លើយ និងការទាមទារសំណងដូចដែលបានទាមទារនៅចំពោះមុខចៅក្រមស៊ើបសួរ ទុកជាបានការដដែល ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ផារ៉ា** បានឆ្លើយថា ខ្ញុំដាក់លុយសរុបមានចំនួន២.៦៥៩.០០០រៀល ដោយបានដាក់ជាច្រើនខែហើយ ។ ចំពោះប្រាក់នោះ គឺបុគ្គលិកខាងសហគ្រាសជាអ្នកទទួល ហើយមានម្ចាស់សហគ្រាស ជាអ្នកមកជាមួយ ហើយមានកិច្ចសន្យា និងសៀវភៅ ដែលចុះ នៅពេលដែលពួកខ្ញុំដាក់ប្រាក់ និងដកប្រាក់ ។ កន្លងមក ពួកខ្ញុំធ្លាប់បានដកប្រាក់ដើម និងការប្រាក់ បានខ្លះ តែលើកចុងក្រោយនេះ បែរជាពុំអាចដកលុយបាន ហើយការដកប្រាក់ គឺពួក



Scanned with CamScanner

ខ្ញុំបានជូនដំណឹងទៅខាងសហគ្រាសជាមុន ។ ខ្ញុំសូមរក្សាចម្លើយ និងការទាមទារសំណងដូចដែលបានទាមទារនៅចំពោះមុខចៅក្រមស៊ើបសួរ ទុកជាបានការដដែល ។

**-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា៖** ក្រោយពីបានស្តាប់ការពិភាក្សាដេញដោល ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់ តំណាងអយ្យការយល់ឃើញថា តាមចម្លើយពេលសវនាការរបស់ជនជាប់ចោទ និងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី អាចបញ្ជាក់បានថា ជនជាប់ចោទពិតជាបានប្រព្រឹត្តអំពើដូចការចោទប្រកាន់របស់តំណាងអយ្យការពិតប្រាកដមែន ។ ដូចនេះតំណាងអយ្យការសុំតម្កល់បទចោទ និងដីកាសន្និដ្ឋានស្ថាពររបស់តំណាងអយ្យការទុកជាបានការដដែល និងប្តឹងសុំចៅក្រមជំនុំជម្រះពិចារណាសម្រេចទៅតាមនីតិវិធី ព្រមទាំងចេញដីកាបង្គាប់ឲ្យចាប់ខ្លួនលើជនជាប់ចោទឈ្មោះ [redacted]ផល្លី ដើម្បីយកមកទទួលខុសត្រូវចំពោះមុខច្បាប់ ។

-លោកមេធាវី [redacted] ជាមេធាវីការពារឲ្យជនជាប់ចោទឈ្មោះ [redacted] ចាន់ បានធ្វើសេចក្តីសន្និដ្ឋានការពារថា ក្រោយពីបានស្តាប់ការពិភាក្សាដេញដោល ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ ឃើញថា កាលពីអំឡុងឆ្នាំ២០២២ និងអំឡុងឆ្នាំ២០២៣ នៅភូមិកំពោតជ្រូក សង្កាត់ព្រៃអង្គុញ ក្រុងបាវិត ខេត្តស្វាយរៀង កូនក្តីខ្ញុំបាទ ពុំបានប្រព្រឹត្តអំពើរំលោភលើទំនុកចិត្តដូចការចោទប្រកាន់របស់តំណាងអយ្យការនោះឡើយ ។ ដោយហេតុថា ផ្អែកតាមចម្លើយរបស់កូនក្តីខ្ញុំបាទ គឺគ្រាន់តែបុគ្គលិករបស់ក្រុមហ៊ុនប៉ុណ្ណោះ ហើយកន្លែងការងាររបស់ខ្លួន គឺនៅខេត្តកំពង់ចាមនោះទេ ពុំមែននៅខេត្តស្វាយរៀងឡើយ ដោយដំបូងឡើយ ខាងក្រុមហ៊ុនបានចាត់តាំង និងបញ្ជូនកូនក្តីខ្ញុំបាទមកឲ្យនិយាយជាមួយភាគីជនរងគ្រោះ ដើម្បីសម្របសម្រួលជាមួយភាគីជនរងគ្រោះ សុំឲ្យភាគីជនរងគ្រោះទុកពេល ដើម្បីឲ្យក្រុមហ៊ុនរកប្រាក់សងទៅអតិថិជនវិញ។ ហើយការមកសម្របសម្រួលនេះ គឺកូនក្តីខ្ញុំធ្វើឡើង តាមការចាត់តាំងរបស់ថ្នាក់លើរបស់គាត់ប៉ុណ្ណោះ ចំណែករឿងដែលជនរងគ្រោះដាក់ប្រាក់បញ្ញើនៅក្រុមហ៊ុននោះ គឺកូនក្តីខ្ញុំបាទពុំបានដឹងអ្វីសោះឡើយ ។ ហើយអ្នកដែលទទួលបន្ទុកការងារក្រុមហ៊ុននៅសាខាខេត្តស្វាយរៀងនេះ ក៏ពុំមែនជាកូនក្តីរបស់ខ្លួននោះដែរ ដោយការងារនេះ គឺឈ្មោះ [redacted]ផល្លី ជាអ្នកចាត់ចែងទាំងស្រុង ហើយការបើកទទួលប្រាក់បញ្ញើ និងចងការប្រាក់នោះក៏ពុំមែនជាគោលការណ៍របស់ក្រុមហ៊ុននោះដែរ គឺអនុវត្តនៅតែខេត្តស្វាយរៀងនេះប៉ុណ្ណោះ ។ ម្យ៉ាងវិញទៀត តាមចម្លើយរបស់ជនរងគ្រោះ នៅក្នុងរឿងនេះ ក៏បានបញ្ជាក់ថា កូនក្តីខ្ញុំពុំមែនជាអ្នកទទួលប្រាក់បញ្ញើពីពួកគាត់នោះឡើយ ហើយក៏ពុំដែលបានឃើញកូនក្តីខ្ញុំធ្វើការនៅក្រុមហ៊ុនសាខាខេត្តស្វាយរៀង នោះដែរ ។ ហេតុដូចនេះ តាមការលើកឡើងខាងលើ បានបង្ហាញឲ្យឃើញថា កូនក្តីខ្ញុំពុំមានចេតនាទុច្ចរិតណាមួយ ក្នុងការប្រព្រឹត្តអំពើរំលោភលើទំនុកចិត្តទៅលើជនរងគ្រោះនោះទេ ដោយនៅក្នុងរឿងនេះ គឺកូនក្តីខ្ញុំពុំបានដឹងអ្វីនោះឡើយ ហើយតាមការពិនិត្យទៅលើអង្គហេតុ និងភស្តុតាងនានានៅក្នុងសំណុំរឿង ឃើញថា រឿងនេះ គឺកើតចេញពីការដាក់បញ្ញើប្រាក់ ទទួលបានការប្រាក់ ហើយនៅពេលដែលក្រុមហ៊ុនរកប្រាក់មកសងអតិថិជនខ្លួនពុំទាន់ ក៏កើតចេញជារឿងហេតុចោទប្រកាន់ពីបទរំលោភលើទំនុកចិត្តតែម្តង ដែលតាមជាក់ស្តែងអង្គហេតុនេះ គឺកើតចេញពីការមិនអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យាប៉ុណ្ណោះ ។ ហេតុដូចនេះ ផ្អែកតាមសំអាងហេតុទាំងអស់នេះ តាមនាមខ្ញុំបាទជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ស្នើសុំតុលាការសម្រេចឲ្យជនជាប់ចោទឈ្មោះ [redacted] ចាន់ បានរួចផុតពីបទចោទប្រកាន់ និងដោះលែងកូនក្តីខ្ញុំបាទឲ្យមានសេរីភាពវិញ ដើម្បីឲ្យកូនក្តីខ្ញុំត្រលប់ទៅផ្ទះវិញ។

-លោកមេធាវី [redacted] ជាមេធាវីការពារឲ្យជនជាប់ចោទឈ្មោះ [redacted] ផល្លី បានធ្វើសេចក្តីសន្និដ្ឋានការពារថា ក្រោយពីបានស្តាប់ការពិភាក្សាដេញដោល ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ ឃើញថា ទាក់ទងនៅក្នុងអង្គហេតុនេះ គឺមានការពាក់ព័ន្ធនឹងការដកប្រាក់ និងដាក់ប្រាក់ ទៅឲ្យអតិថិជន ហើយរឿង



Scanned with CamScanner

ហេតុនេះ គឺកូនក្តីខ្ញុំពុំមានចេតនាណាមួយប្រព្រឹត្តអំពើរំលោភលើសេចក្តីទុកចិត្តទៅអតិថិជនដែលជាម្ចាស់បំណុលនោះទេ ប៉ុន្តែដោយសារក្រុមហ៊ុនកូនក្តីខ្ញុំបាទ ជួបវិបត្តិ និងបង្វិលប្រាក់ពីអតិថិជនរបស់ខ្លួនពុំទាន់ ក៏ពុំមានលទ្ធភាពសងប្រាក់ទៅឱ្យអតិថិជនខ្លួនពុំទាន់ ហើយកន្លងមក កូនក្តីខ្ញុំបាទ ក៏បានព្យាយាមធ្វើការសម្របសម្រួលជាមួយភាគីជនរងគ្រោះ សុំទុករយៈពេលឱ្យកូនក្តីខ្លួនដើម្បីរកប្រាក់សងទៅពួកគាត់វិញ តែពួកគាត់ពុំព្រម និងទាមទារឱ្យកូនក្តីខ្លួនបង់ប្រាក់ទៅឱ្យពួកគាត់តាមការកំណត់ ទើបកូនក្តីខ្ញុំពុំមានលទ្ធភាពសង ហើយក៏ត្រូវបានពួកគាត់ប្តឹងមកតុលាការ ដែលកើតចេញជារឿងហេតុចោទប្រកាន់ពីបទរំលោភលើទំនុកចិត្តតែម្តង ។ ហេតុដូច្នេះ ខ្ញុំបាទជាមេធាវីសំណូមពរតុលាការមេត្តាផ្តន្ទាទោសកូនក្តីខ្ញុំឱ្យបានទាប និងស្នើសុំអនុវត្តការព្យួរទោសមកលើកូនក្តីខ្ញុំបាទផង ។

-ជនជាប់ចោទឈ្មោះ [redacted] ចាន់ បាននិយាយសំដីចុងក្រោយថា៖សំណូមពរដល់តុលាការមេត្តាលើកលែងការចោទប្រកាន់មកលើរូបខ្ញុំបាទ ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ ។

-ក្រោយពីបានស្តាប់ចម្លើយ និងអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ ។

-ក្រោយពីបានពិនិត្យឯកសារភស្តុតាងត្រឹមត្រូវហើយ ។

-ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

## សំអាងហេតុ

**-យល់ឃើញថា** តាមមាត្រា **៣៧៧** នៃក្រមព្រហ្មទណ្ឌ ចែងថា “អំពើឆបោក គឺជាអំពើបន្លំចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយ ដោយប្រើឈ្មោះក្លែង ដោយអះអាងទៅលើឋានៈក្លែង ដោយរំលោភលើឋានៈពិតប្រាកដ ឬដោយប្រើឧបាយកលទុច្ចរិត ហើយដូច្នេះបានទទួលពីបុគ្គលនេះ ដែលនាំឱ្យខូចប្រយោជន៍របស់បុគ្គលនេះ ឬរបស់តតិយជននូវ៖ ១-ការប្រគល់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ។ ២-ការផ្តត់ផ្គង់សេវា។ ៣-ការធ្វើលិខិតដែលមានតម្លៃជាកាតព្វកិច្ច ឬជាការឱ្យរួចផុតពីកាតព្វកិច្ច”។ ហើយតាមមាត្រា **៣៧៨** នៃក្រមដដែលនេះ ចែងថា “អំពើឆបោក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី១.០០០.០០០(មួយលាន)រៀល ទៅ៦.០០០.០០០(ប្រាំមួយលាន) រៀល”។

-តាមរបាយការណ៍សំយោគលេខ **១១៥ របក** ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៣ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាល នៃស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង បានសន្និដ្ឋានថា ជនជាប់ចោទឈ្មោះ [redacted] ចាន់ ភេទប្រុស អាយុ៤៤ឆ្នាំ ជនជាតិខ្មែរ និងបក្សពួក ពិតជាបានប្រព្រឹត្តអំពើ **ឆបោកប្រាក់** ប្រព្រឹត្តនៅភូមិកំពោតជ្រូក សង្កាត់ព្រៃអង្គុញ ក្រុងបាវិត ខេត្តស្វាយរៀង កាលពីអំឡុងឆ្នាំ២០២២ និងអំឡុងឆ្នាំ២០២៣ ប្រាកដមែន ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted]ចាន់ បានឆ្លើយគ្រប់ដំណាក់កាលនីតិវិធី និងនាពេលសវនាការថា ដំបូងឡើយ ខាងក្រុមហ៊ុនបានបញ្ជូនខ្លួនមកឱ្យនិយាយជាមួយភាគីជនរងគ្រោះ សុំពន្យារពេលគាត់ ហើយមកបាន២ថ្ងៃ ក៏ត្រូវគេឃាត់ខ្លួន ។ ពីមុន ខ្លួនធ្វើការនៅខេត្តកំពង់ចាម ពីឆ្នាំ២០២០ មកដល់ពេលនេះ បាន៤ឆ្នាំ ដោយកាន់តួនាទីជានាយកសាខា ហើយក្រុមហ៊ុននេះ គឺផ្តល់សេវាកម្ចីប្រាក់ ដោយឱ្យការប្រាក់ចាប់ពី១.៥ភាគរយឡើង ។ ហើយទឹកប្រាក់ដែលទទួល គឺចាប់ពី២០ម៉ឺនរៀល ដល់១លានរៀល ។ ជាគោលការណ៍លុយបង្វិល គឺ១សប្តាហ៍ ឱ្យទៅខាងអ្នកដាក់បញ្ញើដោយដកទាំងដើម និងការប្រាក់ ហើយដាក់បន្ត។ ចំពោះនៅខេត្តកំពង់ចាម គឺពុំមានការដាក់បញ្ញើនេះនោះទេ ។ ចំពោះ

ប្រាក់បញ្ញើនេះ គឺនៅស្វាយរៀងនោះទេ ហើយខ្លួនមកធ្វើការនៅខេត្តកំពង់ចាមនោះទេ តែថ្នាក់លើឱ្យខ្លួនមកដោះស្រាយនៅខេត្តស្វាយរៀង ដោយមកនិយាយជាមួយអតិថិជនឱ្យជួយសម្របសម្រួលរឿងការងារបង្វិលប្រាក់ទៅពលរដ្ឋពុំទាន់ ។ ក្រុមហ៊ុននៅបាវិត គឺនៅបើកធម្មតា តែចំពោះសេវាកម្មបញ្ញើនេះ គឺផ្អាកទទួល។ ចំពោះរយៈពេល២ថ្ងៃដែលមកធ្វើការនៅខេត្តស្វាយរៀងនេះ គឺបានមកសម្របសម្រួលជាមួយអតិថិជន។ ហើយចំពោះចំនួនទឹកប្រាក់ គឺខ្លួនពុំទាន់បានដឹងថាចំនួនប៉ុន្មាននោះទេ ។ ចំពោះការដកប្រាក់ គឺនាយកសាខា អាចដកប្រាក់ចំណាយបានតិចតួច ទាល់តែនាយកធំខាងលើបានអាចដកបានចំពោះការរកប្រាក់សងពុំបាននេះ គឺដោយសារខាងអតិថិជន ពុំបានសងមកក្រុមហ៊ុនទាន់ពេលវេលាដែរ។ ខ្លួនមានតួនាទីជានាយកសាខា នៅខេត្តកំពង់ចាម ហើយនៅស្វាយរៀង មានការកកស្ទះរឿងប្រាក់ ក៏គេចាត់ឱ្យខ្លួនមក ។ ចំពោះការចោទប្រកាន់នេះ ពុំត្រឹមត្រូវនោះទេ ដោយសារខ្លួនពុំមែនជាអ្នកតួនាទីនៅខេត្តស្វាយរៀងនោះទេ គឺឈ្មោះ[redacted] សុជាតិ ជានាយកសាខានៅស្វាយរៀង ហើយឈ្មោះ [redacted] ផល្លី ជាអ្នកទទួលខុសត្រូវរួម ដោយសារគាត់ជាអគ្គនាយកក្រុមហ៊ុន ។ ចំពោះការបាត់ប្រាក់នោះ គឺខ្លួនពុំបានដឹងនោះទេ តែដឹងត្រឹមថា លុយនោះ គឺបានយកទៅឱ្យអតិថិជនខ្ចី ហើយពួកគាត់ពុំទាន់បានសងមកក្រុមហ៊ុនវិញ តាមពេលកំណត់ ។ ហើយក៏ពុំបានរកឃើញថា មានការបាត់បង់ដោយសារការយកទៅចាយវាយផ្ទាល់ខ្លួននោះដែរ ។ ខ្លួនមកនេះ ដើម្បីសុំការពន្យារពេល ដើរប្រមូលប្រាក់ ទៅបង្វិលជូនពួកគាត់ ។ ខាងក្រុមហ៊ុន ពុំបានប្តូរទីតាំងនោះទេ ។ ខ្លួនធ្វើការបានប្រាក់ខែ៤០០ដុល្លារក្នុង១ខែ ។ ហើយការងារ គឺខ្លួនទទួលខុសត្រូវតែនៅខេត្តកំពង់ចាមនោះទេ តែខាងក្រុមហ៊ុន ក៏បានចាត់ឱ្យខ្លួនមកដោះស្រាយបញ្ហាអតិថិជននៅខេត្តស្វាយរៀង ។ ចំពោះប្រាក់ដែលដើមបណ្តឹងប្តឹងទាមទារនោះ គឺខ្លួនពុំបានទទួលនោះទេ ហើយអ្នកទទួល គឺបុគ្គលិកដែលធ្វើការនៅខេត្តស្វាយរៀង ។ ក្រុមហ៊ុននៅខេត្តកំពង់ចាម ខ្លួនពុំដឹងថា មានអាជ្ញាប័ណ្ណ ឬអត់ទេ ដោយសារខ្លួនជាបុគ្គលិកថ្នាក់ក្រោម។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]សុវណ្ណ បានឆ្លើយថា ខ្លួនដាក់លុយសរុបមានចំនួន១.៤៦០.០០០រៀល ដោយបានដាក់ជាច្រើនខែហើយ ។ ចំពោះប្រាក់នោះ គឺបុគ្គលិកខាងសហគ្រាសជាអ្នកទទួល ហើយមានម្ចាស់សហគ្រាស ជាអ្នកមកជាមួយ ហើយមានកិច្ចសន្យា និងសៀវភៅ ដែលចុះ នៅពេលដែលពួកខ្លួនដាក់ប្រាក់ និងដកប្រាក់ ។ ខ្លួនសូមរក្សាចម្លើយ និងការទាមទារសំណងដូចដែលបានទាមទារនៅចំពោះមុខចៅក្រមស៊ើបសួរ ទុកជាបានការដដែល ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សិរី បានឆ្លើយថា ខ្លួនដាក់លុយសរុបមានចំនួន២.០១០.០០០រៀល ដោយបានដាក់ជាច្រើនខែហើយ ។ ចំពោះប្រាក់នោះ គឺបុគ្គលិកខាងសហគ្រាសជាអ្នកទទួល ហើយមានម្ចាស់សហគ្រាស ជាអ្នកមកជាមួយ ហើយមានកិច្ចសន្យា និងសៀវភៅ ដែលចុះ នៅពេលដែលពួកខ្លួនដាក់ប្រាក់ និងដកប្រាក់ ។ ខ្លួនសូមរក្សាចម្លើយ និងការទាមទារសំណងដូចដែលបានទាមទារនៅចំពោះមុខចៅក្រមស៊ើបសួរ ទុកជាបានការដដែល ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាមី បានឆ្លើយថា ខ្លួនដាក់លុយសរុបមានចំនួន២.៨០០.០០០រៀល ដោយបានដាក់ជាច្រើនខែហើយ ។ ចំពោះប្រាក់នោះ គឺបុគ្គលិកខាងសហគ្រាសជាអ្នកទទួល ហើយមានម្ចាស់សហគ្រាស ជាអ្នកមកជាមួយ ហើយមានកិច្ចសន្យា និងសៀវភៅ ដែលចុះ នៅពេលដែលពួកខ្លួនដាក់ប្រាក់ និងដកប្រាក់ ។ ខ្លួនសូមរក្សាចម្លើយ និងការទាមទារសំណងដូចដែលបានទាមទារនៅចំពោះមុខចៅក្រមស៊ើបសួរ ទុកជាបានការដដែល ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] គន្ធា បានឆ្លើយថា ខ្លួនដាក់លុយសរុបមានចំនួន៦.០១៥.០០០រៀល ដោយបានដាក់ជាច្រើនខែហើយ ។ ចំពោះប្រាក់នោះ គឺបុគ្គលិកខាងសហគ្រាសជាអ្នកទទួល ហើយមានម្ចាស់សហគ្រាស ជាអ្នកមកជាមួយ ហើយមានកិច្ចសន្យា និងសៀវភៅ ដែលចុះ នៅពេលដែលពួកខ្លួនដាក់ប្រាក់ និងដកប្រាក់ ។ ខ្លួនចូលរួមប្តឹង

ដោយសារខ្លួនដកប្រាក់ពុំបាន ហើយនៅពេលដាក់ គឺបានចំនួន១០ថ្ងៃ ហើយពេលទៅដក គឺដកពុំបាន តែក្រោយមក នៅពេលបាន៨ថ្ងៃ ហើយទៅដក ដកពុំបាន ក៏បានប្តឹងតែម្តង ។ ខ្លួនសូមរក្សាចម្លើយ និងការទាមទារសំណងដូចដែលបានទាមទារនៅចំពោះមុខចៅក្រមស៊ើបសួរ ទុកជាបានការដដែល ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] នាត បានឆ្លើយថា ខ្លួនដាក់លុយសរុបមានចំនួន៥១០.០០០រៀល ដោយបានដាក់ជាច្រើនខែហើយ ។ ចំពោះប្រាក់នោះ គឺបុគ្គលិកខាងសហគ្រាសជាអ្នកទទួល ហើយមានម្ចាស់សហគ្រាស ជាអ្នកមកជាមួយ ហើយមានកិច្ចសន្យា និងសៀវភៅ ដែលចុះ នៅពេលដែលពួកខ្លួនដាក់ប្រាក់ និងដកប្រាក់ ។ ខ្លួនសូមរក្សាចម្លើយ និងការទាមទារសំណងដូចដែលបានទាមទារនៅចំពោះមុខចៅក្រមស៊ើបសួរ ទុកជាបានការដដែល ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ធឿន បានឆ្លើយថា ខ្លួនដាក់លុយសរុបមានចំនួន៥១០.០០០រៀល ដោយបានដាក់ជាច្រើនខែហើយ ។ ចំពោះប្រាក់នោះ គឺបុគ្គលិកខាងសហគ្រាសជាអ្នកទទួល ហើយមានម្ចាស់សហគ្រាស ជាអ្នកមកជាមួយ ហើយមានកិច្ចសន្យា និងសៀវភៅ ដែលចុះ នៅពេលដែលពួកខ្លួនដាក់ប្រាក់ និងដកប្រាក់ ។ ខ្លួនសូមរក្សាចម្លើយ និងការទាមទារសំណងដូចដែលបានទាមទារនៅចំពោះមុខចៅក្រមស៊ើបសួរ ទុកជាបានការដដែល ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុវណ្ណារ៉ា បានឆ្លើយថា ខ្លួនដាក់លុយសរុបមានចំនួន២.៥៣០.០០០រៀល ដោយបានដាក់ជាច្រើនខែហើយ ។ ចំពោះប្រាក់នោះ គឺបុគ្គលិកខាងសហគ្រាសជាអ្នកទទួល ហើយមានម្ចាស់សហគ្រាស ជាអ្នកមកជាមួយ ហើយមានកិច្ចសន្យា និងសៀវភៅ ដែលចុះ នៅពេលដែលពួកខ្លួនដាក់ប្រាក់ និងដកប្រាក់ ។ ចំពោះឈ្មោះ [redacted] ចាន់ គឺពេលខ្លួនទៅដាក់ គឺខ្លួនធ្លាប់ជួបគាត់ច្រើនដង ហើយដោយសារគាត់ជាបងប្អូនគ្នា ចឹង ពេលខ្លះទៅជួបគាត់ ពេលខ្លះទៅជួបបងប្អូនរបស់គាត់ តែខ្លួនឃើញគាត់នៅធ្វើការកន្លែងនោះ ។ កន្លងមក ពួកខ្លួនដកប្រាក់បាន គឺចំណេញ តែនៅពេលដែលដកពុំបាន ទើបធ្វើឱ្យពួកខ្លួនខាតបង់ប្រយោជន៍ ។ ខ្លួនសូមរក្សាចម្លើយ និងការទាមទារសំណងដូចដែលបានទាមទារនៅចំពោះមុខចៅក្រមស៊ើបសួរ ទុកជាបានការដដែល ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ីទួន បានឆ្លើយថា ខ្លួនដាក់លុយសរុបមានចំនួន១.៥១០.០០០រៀល ដោយបានដាក់ជាច្រើនខែហើយ ។ ចំពោះប្រាក់នោះ គឺបុគ្គលិកខាងសហគ្រាសជាអ្នកទទួល ហើយមានម្ចាស់សហគ្រាស ជាអ្នកមកជាមួយ ហើយមានកិច្ចសន្យា និងសៀវភៅ ដែលចុះ នៅពេលដែលពួកខ្លួនដាក់ប្រាក់ និងដកប្រាក់ ។ ខ្លួនសូមរក្សាចម្លើយ និងការទាមទារសំណងដូចដែលបានទាមទារនៅចំពោះមុខចៅក្រមស៊ើបសួរ ទុកជាបានការដដែល ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាវ៉ន បានឆ្លើយថា ខ្លួនដាក់លុយសរុបមានចំនួន២.១០០.០០០រៀល ដោយបានដាក់ជាច្រើនខែហើយ ។ ចំពោះប្រាក់នោះ គឺបុគ្គលិកខាងសហគ្រាសជាអ្នកទទួល ហើយមានម្ចាស់សហគ្រាស ជាអ្នកមកជាមួយ ហើយមានកិច្ចសន្យា និងសៀវភៅ ដែលចុះ នៅពេលដែលពួកខ្លួនដាក់ប្រាក់ និងដកប្រាក់ ។ ខ្លួនសូមរក្សាចម្លើយ និងការទាមទារសំណងដូចដែលបានទាមទារនៅចំពោះមុខចៅក្រមស៊ើបសួរ ទុកជាបានការដដែល ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាផាន បានឆ្លើយថា ខ្លួនដាក់លុយសរុបមានចំនួន៤.៥០០.០០០រៀល ដោយបានដាក់ជាច្រើនខែហើយ ។ ចំពោះប្រាក់នោះ គឺបុគ្គលិកខាងសហគ្រាសជាអ្នកទទួល ហើយមានម្ចាស់សហគ្រាស ជាអ្នកមកជាមួយ ហើយមានកិច្ចសន្យា និងសៀវភៅ ដែលចុះ នៅពេលដែលពួកខ្លួនដាក់ប្រាក់ និងដកប្រាក់ ។ កន្លងមក ពួកខ្លួនធ្លាប់បានដកប្រាក់ដើម និងការប្រាក់ បានខ្លះ តែលើកចុងក្រោយនេះ បែរជាពុំអាចដកលុយបាន ហើយការដកប្រាក់ គឺ



Scanned with CamScanner

ពួកខ្លួនបានជូនដំណឹងទៅខាងសហគ្រាសជាមុន ។ ខ្លួនសូមរក្សាចម្លើយ និងការទាមទារសំណងដូចដែលបានទាមទារនៅចំពោះមុខចៅក្រមស៊ើបសួរ ទុកជាបានការដដែល ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **មករា** បានឆ្លើយថា ខ្លួនដាក់លុយសរុបមានចំនួន៦.៨០០.០០០រៀល ដោយបានដាក់ជាច្រើនខែហើយ ។ ចំពោះប្រាក់នោះ គឺបុគ្គលិកខាងសហគ្រាសជាអ្នកទទួល ហើយមានម្ចាស់សហគ្រាស ជាអ្នកមកជាមួយ ហើយមានកិច្ចសន្យា និងសៀវភៅ ដែលចុះ នៅពេលដែលពួកខ្លួនដាក់ប្រាក់ និងដកប្រាក់ ។ កន្លងមក ពួកខ្លួនធ្លាប់បានដកប្រាក់ដើម និងការប្រាក់ បានខ្លះ តែលើកចុងក្រោយនេះ បែរជាពុំអាចដកលុយបាន ហើយការដកប្រាក់ គឺពួកខ្លួនបានជូនដំណឹងទៅខាងសហគ្រាសជាមុន ។ ខ្លួនសូមរក្សាចម្លើយ និងការទាមទារសំណងដូចដែលបានទាមទារនៅចំពោះមុខចៅក្រមស៊ើបសួរ ទុកជាបានការដដែល ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាបុល បានឆ្លើយថា ខ្លួនដាក់លុយសរុបមានចំនួន៣.៩២៤.០០០រៀល ដោយបានដាក់ជាច្រើនខែហើយ ។ ចំពោះប្រាក់នោះ គឺបុគ្គលិកខាងសហគ្រាសជាអ្នកទទួល ហើយមានម្ចាស់សហគ្រាស ជាអ្នកមកជាមួយ ហើយមានកិច្ចសន្យា និងសៀវភៅ ដែលចុះ នៅពេលដែលពួកខ្លួនដាក់ប្រាក់ និងដកប្រាក់ ។ កន្លងមក ពួកខ្លួនធ្លាប់បានដកប្រាក់ដើម និងការប្រាក់ បានខ្លះ តែលើកចុងក្រោយនេះ បែរជាពុំអាចដកលុយបាន ហើយការដកប្រាក់ គឺពួកខ្លួនបានជូនដំណឹងទៅខាងសហគ្រាសជាមុន ។ ខ្លួនសូមរក្សាចម្លើយ និងការទាមទារសំណងដូចដែលបានទាមទារនៅចំពោះមុខចៅក្រមស៊ើបសួរ ទុកជាបានការដដែល ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ផារ៉ា** បានឆ្លើយថា ខ្លួនដាក់លុយសរុបមានចំនួន២.៦៥៩.០០០រៀល ដោយបានដាក់ជាច្រើនខែហើយ ។ ចំពោះប្រាក់នោះ គឺបុគ្គលិកខាងសហគ្រាសជាអ្នកទទួល ហើយមានម្ចាស់សហគ្រាស ជាអ្នកមកជាមួយ ហើយមានកិច្ចសន្យា និងសៀវភៅ ដែលចុះ នៅពេលដែលពួកខ្លួនដាក់ប្រាក់ និងដកប្រាក់ ។ កន្លងមក ពួកខ្លួនធ្លាប់បានដកប្រាក់ដើម និងការប្រាក់ បានខ្លះ តែលើកចុងក្រោយនេះ បែរជាពុំអាចដកលុយបាន ហើយការដកប្រាក់ គឺពួកខ្លួនបានជូនដំណឹងទៅខាងសហគ្រាសជាមុន ។ ខ្លួនសូមរក្សាចម្លើយ និងការទាមទារសំណងដូចដែលបានទាមទារនៅចំពោះមុខចៅក្រមស៊ើបសួរ ទុកជាបានការដដែល ។

-តាមចម្លើយរបស់ជនជាប់ចោទ និងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី គឺមានភាពស៊ីសង្វាក់ទៅនឹងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងភស្តុតាងក្នុងសំណុំរឿង បញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] ចាន់ ពិតជាបានប្រព្រឹត្តបទ **សមគំនិតក្នុងអំពើឆបោក** និងឈ្មោះ [redacted] **ផល្លី** ពិតជាបានប្រព្រឹត្តបទ **ឆបោក** ប្រព្រឹត្តនៅភូមិកំពោតជ្រូក សង្កាត់ព្រៃអង្គុញ ក្រុងបាវិត ខេត្តស្វាយរៀង កាលពីអំឡុងឆ្នាំ២០២២ និងអំឡុងឆ្នាំ២០២៣ បទល្មើសដែលមានចែងនិងបញ្ញត្តឱ្យផ្តន្ទាទោសតាមមាត្រា **២៩** មាត្រា **៣៧៧** និងមាត្រា **៣៧៨** នៃក្រមព្រហ្មទណ្ឌ ប្រាកដមែន ។

-**យល់ឃើញពីសេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ** បានប្តឹងសុំរក្សាបទចោទ និងតម្កល់ដីកាសន្និដ្ឋានស្ថាពររបស់តំណាងអយ្យការទុកជាបានការដដែល និងប្តឹងសុំចៅក្រមជំនុំជម្រះផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ចាន់ បទ **សមគំនិតក្នុងអំពើឆបោក** និងឈ្មោះ [redacted] ផល្លី ពីបទ **ឆបោក** ប្រព្រឹត្តនៅភូមិកំពោតជ្រូក សង្កាត់ព្រៃអង្គុញ ក្រុងបាវិត ខេត្តស្វាយរៀង កាលពីអំឡុងឆ្នាំ២០២២ និងអំឡុងឆ្នាំ២០២៣ បទល្មើសដែលមានចែងនិងបញ្ញត្តឱ្យផ្តន្ទាទោសតាមមាត្រា **២៩** មាត្រា **៣៧៧** និងមាត្រា **៣៧៨** នៃក្រមព្រហ្មទណ្ឌ ។ ការប្តឹងសុំរបស់តំណាងអយ្យការមានភាពសមរម្យ ដែលអាចឱ្យតុលាការពិចារណាសម្រេចបាន ។

-**យល់ឃើញពីសមត្ថភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ៖** តាមនីតិវិធីនៅដំណាក់កាលសមត្ថកិច្ច ដំណាក់កាលអយ្យការ ដំណាក់កាលចៅក្រមស៊ើបសួរ និងនាពេលសវនាការ ឃើញថា ជនជាប់ចោទឈ្មោះ [redacted] ចាន់ និងឈ្មោះ



Scanned with CamScanner

[redacted] ផល្លី គឺជានីតិជន មានស្មារតីគ្រប់គ្រាន់ដោយពុំមានសញ្ញាណណាមួយបញ្ជាក់មានបញ្ហាវិបល្លាសស្មារតីឡើយ ដូច្នេះ ជនជាប់ចោទត្រូវទទួលខុសត្រូវចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត ដូចមានចែងក្នុងមាត្រា ២៤ នៃក្រមព្រហ្មទណ្ឌ ។

**-យល់ឃើញថា** ជនជាប់ចោទឈ្មោះ [redacted] ចាន់ បានឆ្លើយបដិសេធនូវការចោទប្រកាន់ និងជនជាប់ចោទឈ្មោះ [redacted] ផល្លី បានរត់គេចខ្លួន បំណងគេចវេះពីការទទួលខុសត្រូវព្រហ្មទណ្ឌ។ ចេតនា និងអំពើរបស់ជនជាប់ចោទគឺជាការប្រព្រឹត្តបទ **ឆបោក** (ប្រាក់) ប៉ះពាល់ដល់ផលប្រយោជន៍របស់ជនរងគ្រោះ និងសណ្តាប់ធ្នាប់សាធារណៈ ។ ហេតុដូច្នេះ គប្បីតុលាការផ្តន្ទាទោសជនជាប់ចោទឱ្យបានសមស្របទៅតាមអំពើ ទំហំព្យសនកម្ម និងកិរិយាមាយាទរបស់ជនជាប់ចោទ ដូចមានចែងក្នុងមាត្រា ៩៦ នៃក្រមព្រហ្មទណ្ឌ និងចេញដីកាបង្គាប់ចាប់ខ្លួនលើជនជាប់ចោទឈ្មោះ [redacted] ផល្លី ដើម្បីយកមកទទួលខុសត្រូវចំពោះមុខច្បាប់ តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**-យល់ឃើញថា** ដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះនៅក្នុងសំណុំរឿងនេះ បានឆ្លើយនាពេលសវនាការ និងនៅចំពោះមុខចៅក្រមស៊ើបសួរ ដើម្បីប្តឹងទាមទារសំណងខូចខាតពីជនជាប់ចោទរួចហើយ ។ ចំពោះការទាមទារសំណងខូចខាតរបស់ដើមបណ្តឹងរដ្ឋប្បវេណីនេះ មានភាពត្រឹមត្រូវទៅតាមផ្លូវច្បាប់ ដែលគប្បីតុលាការសម្រេចអំពីសំណងរដ្ឋប្បវេណីទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឱ្យបានសមស្រមតាមសភាពជាក់ស្តែង និងព្យសនកម្មដែលជនរងគ្រោះទទួលរងដោយផ្អែកតាមមាត្រា ៣៥៥ នៃក្រមនិតិវិធីព្រហ្មទណ្ឌ ។

**-យល់ឃើញថា** វត្ថុចាប់យកដូចមានក្នុងកំណត់ហេតុទទួលវត្ថុចាប់យកលេខ ៣០០ អ.យ.ច ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៣ ដែលមាន៖ ទូរស័ព្ទចំនួន០១(មួយ)គ្រឿង ម៉ាក VIVO ពណ៌ខ្មៅ សំបកក្រហមលាយឈាមជ្រូក និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ(លេខ០៦១៧២២០១០)ចំនួន១សន្លឹក ដែលដកហូតបានពីជនជាប់ចោទ គឺពុំមានពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើស គប្បីតុលាការប្រគល់ទៅឱ្យម្ចាស់ដើមវិញ តាមមាត្រា ៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ចាន់ ពីបទ **សមគំនិតក្នុងអំពើឆបោក** ប្រព្រឹត្តនៅភូមិកំពោតជ្រូក សង្កាត់ព្រៃអង្គុញ ក្រុងបាវិត ខេត្តស្វាយរៀង កាលពីអំឡុងឆ្នាំ២០២២ និងអំឡុងឆ្នាំ២០២៣ បទល្មើសមានចែងនិងផ្តន្ទាទោសតាមមាត្រា២៩ មាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ និងឈ្មោះ [redacted] ផល្លី ពីបទ **ឆបោក** ប្រព្រឹត្តនៅភូមិកំពោតជ្រូក សង្កាត់ព្រៃអង្គុញ ក្រុងបាវិត ខេត្តស្វាយរៀង កាលពីអំឡុងឆ្នាំ២០២២ និងអំឡុងឆ្នាំ២០២៣ បទល្មើសដែលមានចែងនិងផ្តន្ទាទោសតាមមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

## ហេតុដូច្នេះសម្រេច

**១-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ** [redacted] ចាន់ ភេទប្រុស អាយុ៤៤ឆ្នាំ ជនជាតិខ្មែរ ជានីតិជន (មានសាវតារជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់២(**ពីរ**)**ឆ្នាំ** និងពិន័យជាប្រាក់ចំនួន២.០០០.០០០(ពីរលាន)រៀល ពីបទ **សមគំនិតក្នុងអំពើឆបោក** ប្រព្រឹត្តនៅភូមិកំពោតជ្រូក សង្កាត់ព្រៃអង្គុញ ក្រុងបាវិត ខេត្តស្វាយរៀង កាលពីអំឡុងឆ្នាំ២០២២ និងអំឡុងឆ្នាំ២០២៣ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា២៩ មាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ។

**២-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ** [redacted] ផល្លី ហៅ រស់ ភេទប្រុស អាយុ៤០ឆ្នាំ ជនជាតិខ្មែរ ជានីតិជន (មានសាវតារជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់២(**ពីរ**)**ឆ្នាំ**៦(**ប្រាំមួយ**)**ខែ** និងពិន័យជាប្រាក់ចំនួន៥.០០០.០០០(ប្រាំលាន)រៀល ពីបទ **ឆបោក** ប្រព្រឹត្តនៅភូមិកំពោតជ្រូក សង្កាត់ព្រៃអង្គុញ ក្រុងបាវិត ខេត្តស្វាយរៀង កាលពីអំឡុងឆ្នាំ២០២២ និងអំឡុងឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ។



Scanned with CamScanner

៣-បង្គាប់ឱ្យចាប់ខ្លួន-ឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] ផល្លី ហៅ រស់ ភេទប្រុស អាយុ៤០ឆ្នាំ ជនជាតិខ្មែរ ជានីតិជន (មានសាវតារជាតិដូចខាងលើ) តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**៤-បញ្ឈប់**ដីកាបង្គាប់ចាប់ខ្លួនលេខ ៥០ បគ.ចឧ/២៤ ចុះថ្ងៃទី២៩-០១-២០២៤ របស់ចៅក្រមស៊ើបសួរ សាលាដំបូងខេត្តស្វាយរៀង ។

៥-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] ចាន់ ភេទប្រុស អាយុ៤៤ឆ្នាំ ជនជាតិខ្មែរ ជានីតិជន (មានសាវតារជាតិដូចខាងលើ) និងជនជាប់ចោទឈ្មោះ [redacted] ផល្លី ហៅ រស់ ភេទប្រុស អាយុ៤០ឆ្នាំ ជនជាតិខ្មែរ ជានីតិជន (មានសាវតារជាតិដូចខាងលើ) រួមគ្នាសងសំណងការខូចខាតឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីដូចខាងក្រោម៖

៥.១-ឈ្មោះ [redacted] សុវណ្ណារ៉ា ចំនួន២.៥៣០.០០០(ពីរលានប្រាំសែនបីម៉ឺន)រៀល ។

៥.២-ឈ្មោះ [redacted]គន្ធា ចំនួន៦.០១៥.០០០(ប្រាំមួយលានមួយម៉ឺនប្រាំពាន់)រៀល ។

៥.៣-ឈ្មោះ [redacted] ធឿន ចំនួន៥១០.០០០(ប្រាំសែនមួយម៉ឺន)រៀល ។

៥.៤-ឈ្មោះ [redacted] ទាត ចំនួន៥១០.០០០(ប្រាំសែនមួយម៉ឺន)រៀល ។

៥.៥-ឈ្មោះ [redacted] សាផាន ចំនួន៤.៥០០.០០០(បួនលានប្រាំសែន)រៀល ។

៥.៦-ឈ្មោះ [redacted] សាវ៉ន ចំនួន២.១០០.០០០(ពីរលានមួយសែន)រៀល ។

៥.៧-ឈ្មោះ [redacted] សាមី ចំនួន២.៨០០.០០០(ពីរលានប្រាំបីសែន)រៀល ។

៥.៨-ឈ្មោះ [redacted] សិរី ចំនួន២.០១០.០០០(ពីរលានមួយម៉ឺន)រៀល ។

៥.៩-ឈ្មោះ [redacted] សុវណ្ណ ចំនួន១.៤៦០.០០០(មួយលានបួនសែនប្រាំមួយម៉ឺន)រៀល ។

៥.១០-ឈ្មោះ [redacted] សុជាតា ចំនួន១.២០០.០០០(មួយលានពីរសែន)រៀល ។

៥.១១-ឈ្មោះ [redacted] ប៊ុនញ៉ាក ចំនួន២៧០.០០០(ពីរសែនប្រាំពីរម៉ឺន)រៀល ។

៥.១២-ឈ្មោះ [redacted] សាអែម ចំនួន១០.០០០.០០០(ដប់លាន)រៀល ។

៥.១៣-ឈ្មោះ [redacted] សាបុល ចំនួន៣.៩២៤.០០០(បីលានប្រាំបួនសែនពីរម៉ឺនបួនពាន់)រៀល ។

៥.១៤-ឈ្មោះ [redacted] ផារ៉ា ចំនួន២.៦៥៩.០០០(ពីរលានប្រាំមួយសែនប្រាំម៉ឺនប្រាំបួនពាន់)រៀល ។

៥.១៥-ឈ្មោះ [redacted]មករា ចំនួន៦.៨០០.០០០(ប្រាំមួយលានប្រាំបីសែន)រៀល ។

៥.១៦-ឈ្មោះ [redacted] សំអន ចំនួន៣.៤០០.០០០(បីលានបួនសែន)រៀល ។

៥.១៧-ឈ្មោះ [redacted]សុរិយា ចំនួន១.៨២៥.០០០(មួយលានប្រាំបីសែនពីរម៉ឺនប្រាំពាន់)រៀល ។

៥.១៨-ឈ្មោះ [redacted] សាផា ចំនួន៣.២៥០.០០០(បីលានពីរសែនប្រាំម៉ឺន)រៀល ។

៥.១៩-ឈ្មោះ [redacted] លន់ ចំនួន១.២០០.០០០(មួយលានពីរសែន)រៀល ។

៦-ប្រគល់នូវវត្ថុចាប់យក រួមមាន៖ ទូរស័ព្ទចំនួន០១(មួយ)គ្រឿង ម៉ាក VIVO ពណ៌ខ្មៅ សំបកក្រហមលាយឈាមជ្រូក និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ(លេខ០៦១៧២២០១០)ចំនួន១សន្លឹក **ឱ្យទៅម្ចាស់ដើមវិញ** តាមមាត្រា ៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

សាលក្រមនេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៤ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ចាន់ និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុវណ្ណារ៉ា ឈ្មោះ [redacted] គន្ធា ឈ្មោះ [redacted] ធឿន ឈ្មោះ [redacted] ទាត ឈ្មោះ [redacted] សាផាន ឈ្មោះ [redacted] សាវ៉ន ឈ្មោះ [redacted] សាមី ឈ្មោះ [redacted]សិរី ឈ្មោះ [redacted]សុវណ្ណ ឈ្មោះ



Scanned with CamScanner

[redacted] សុជាតា ឈ្មោះ [redacted] ប៊ុនញ៉ាក ឈ្មោះ [redacted] សារ៉ែម ឈ្មោះ [redacted] សារុល ឈ្មោះ [redacted] ផារ៉ាំ ឈ្មោះ [redacted] មករា ឈ្មោះ [redacted] សំអន ឈ្មោះ [redacted] សុរិយា ឈ្មោះ [redacted] សាផា ឈ្មោះ [redacted] លន់ និងចាត់ទុកជាចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ផល្លី នៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២៤ ។

បើកផ្លូវប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ៕

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និង
[redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា
[redacted]

---

**បានឃើញ**

ថ្ងៃពុធ ១២រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ខេត្តស្វាយរៀង, ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២៤

**ចៅក្រមជំនុំជម្រះ**

[redacted]

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃពុធ ១២រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ខេត្តស្វាយរៀង, ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២៤

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner